**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧១៧ . អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់សហគមន៍ លើផ្ទៃដីទំហំ១ ៥០០ហិកតា ក្នុងតំបន់ដែនជម្រកសត្វព្រៃរនាមដូនសំ ស្ថិតនៅក្នុងឃុំទួលពង្រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៣/២៩១ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការកែសម្រួលផ្ទៃដីតំបន់ដែនជម្រកសត្វព្រៃរនាមដូនសំ ពីផ្ទៃដីទំហំ១៧៨ ៧៥០ហិកតា មកនៅត្រឹម៩០ ០២១ហិកតា
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី៩...ខែកញ្ញាឆ្នាំ២០១១

## ស ម្រេ ច

**មាត្រា ១.-**

អនុលោមតាមព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ត្រង់មាត្រា១១ ចំណុច៤ ត្រូវបានកំណត់ទំហំដី១ ៥០០(មួយពាន់ប្រាំរយ)ហិកតា ជាតំបន់សហគមន៍នៃតំបន់ដែនជម្រកសត្វព្រៃនាមដូនសំស្ថិតនៅក្នុងឃុំទួលពង្រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។

តំបន់សហគមន៍ក្នុងតំបន់ដែនជម្រកសត្វព្រៃនាមដូនសំ មានផែនទីនិងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

Khmer Law's Association

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម
លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# និយាមការកំណត់តំបន់សហគមន៍នៃដែនជម្រកសត្វព្រៃនាមជុនសំ ស្ថិតនៅឃុំទួលពង្រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ លើផ្ទៃដីចំនួន១៥00ហិកតា

| Nº | X | Y | Nº | X | Y |
|---|---|---|---|---|---|
| A | 236003 | 1496000 | K | 244000 | 1491000 |
| B | 237005 | 1496000 | L | 245370 | 1494027 |
| C | 237005 | 1491000 | M | 242508 | 1491000 |
| D | 236003 | 1491000 | N | 245179 | 1493890 |
| E | 242508 | 1496000 | O | 245069 | 1493862 |
| F | 244000 | 1496000 | P | 244905 | 1493603 |
| G | 245718 | 1494367 | Q | 244892 | 1493411 |
| H | 245603 | 1494191 | R | 244536 | 1493137 |
| I | 244000 | 1492895 | S | 244256 | 1493084 |
| J | 245480 | 1494136 | | | |

ផែនទី និងនិយាមការ កំណត់តំបន់សហគមន៍ នៃដែនជម្រកសត្វព្រៃនាងជូនសំ
ស្ថិតនៅក្នុងឃុំគុលពាទ្រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ លើផ្ទៃដីចំនួន ១៥០០ ហិកតា

អនុក្រឹត្យ លេខ: ២១២...អនក្រ.បក
ចុះថ្ងៃទី ១៥ ... ខែ កញ្ញា... ឆ្នាំ ២០១១



| ID | N | X | Y |
|---|---|---|---|
| 1 | A | 236003 | 1496000 |
| 2 | B | 237005 | 1496000 |
| 3 | C | 237005 | 1491000 |
| 4 | D | 236003 | 1491000 |
| 5 | E | 242508 | 1496000. |
| 6 | F | 244000 | 1496000. |
| 7 | G | 245718 | 1494367. |
| 8 | H | 245603 | 1494191. |
| 9 | I | 244000 | 1492895 |
| 9 | J | 245480 | 1494136. |
| 10 | K | 244000 | 1491000 |
| 10 | L | 245370 | 1494027. |
| 11 | M | 242508 | 1491000 |
| 11 | N | 245179 | 1493890. |
| 12 | O | 245069 | 1493862. |
| 13 | P | 244905 | 1493803 |
| 14 | Q | 244892 | 1493411. |
| 15 | R | 244536 | 1493137. |
| 16 | S | 244256 | 1493084. |

បានឃើញ និងឯកភាព
រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ២០១១
ជ. គេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
ឆាន់ សាផាន

បានឃើញ និងឯកភាព
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១១
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងបរិស្ថាន
ផ្ទេរសារាចរ

**សញ្ញាសំគាល់**
- ចំណុចនិយាមកា
- តំបន់សហគមន៍
- ព្រំប្រទល់ដែនជម្រកសត្វព្រៃនាមជូនសំ